ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៤ លេខ ៣២ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៦

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្ដាហ៍

មាតិកា

I .ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

៣០-៨-១៩៩៦- ព្រះរាជក្រឹត្យ នស/រកត/ ០៨៩៦/៦៥ លើកលែងទោស
អោយទណ្ឌិតឈ្មោះ ហែន ទិតាគ ហៅ ហែន តារ: ១៣៧៩

II -ទីស្ដីការគណៈរដ្ឋមន្ត្រី

១_អនុក្រឹត្យ

២៦-៨-១៩៩៦ – អនុក្រឹត្យលេខ ១៥០ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រី
រាជការ ១៣៨០
២៦_៨_១៩៩៦ _ អនុក្រឹត្យលេខ ១៥១ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រី
រាជការ ១៣៨១
២៦_៨_១៩៩៦ _ អនុក្រឹត្យលេខ ១៥២ អនក្រ.តត ស្ដីពីការតែងតាំងទីប្រឹក្សា
រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ១៣៨៤
២៧_៨_១៩៩៦ _ អនុក្រឹត្យលេខ ១៥៣ អនក្រ.តត ស្ដីពីការលុបឈ្មោះមន្ត្រី
រាជការ ១៣៨៥
២៨_៨_១៩៩៦ _ អនុក្រឹត្យលេខ ១៥៤ អនក្រ.តត ស្ដីពីការជូនមេដាយ
ស្ថាបនាជាតិ ១៣៨៦
២៨_៨_១៩៩៦ _ អនុក្រឹត្យលេខ ១៥៥ អនក្រ.តត ស្ដីពីការជូនមេដាយ
ស្ថាបនាជាតិ ១៣៨៧

២៨_៨_១៩៩៦ _ អនុក្រឹត្យលេខ ១៥៦ អនក្រ.តត ស្ដីពីការផ្ដល់មេដាយ
ស្ថាបនាជាតិ ១៣៨៨
២៨_៨_១៩៩៦ _ អនុក្រឹត្យលេខ ១៥៧ អនក្រ.តត ស្ដីពីការផ្ដល់មេដាយ
ស្ថាបនាជាតិ ១៣៩០
២៨_៨_១៩៩៦ _ អនុក្រឹត្យលេខ ១៥៨ អនក្រ.តត ស្ដីពីការផ្ដល់មេដាយ
ស្ថាបនាជាតិ ១៣៩១
២៨_៨_១៩៩៦ _ អនុក្រឹត្យលេខ ១៥៩ អនក្រ.តត ស្ដីពីការផ្ដល់មេដាយ
ស្ថាបនាជាតិ ១៣៩២
២៨_៨_១៩៩៦ _ អនុក្រឹត្យលេខ ១៦០ អនក្រ.តត ស្ដីពីការផ្ដល់មេដាយ
ស្ថាបនាជាតិ ១៣៩៣
២៨_៨_១៩៩៦ _ អនុក្រឹត្យលេខ ១៦១ អនក្រ.តត ស្ដីពីការផ្ដល់មេដាយ
ស្ថាបនាជាតិ ១៣៩៤
២៨_៨_១៩៩៦ _ អនុក្រឹត្យលេខ ១៦២ អនក្រ.តត ស្ដីពីការផ្ដល់មេដាយ
ស្ថាបនាជាតិ ១៣៩៥
២៨_៨_១៩៩៦ _ អនុក្រឹត្យលេខ ១៦៣ អនក្រ.តត ស្ដីពីការផ្ដល់មេដាយ
ស្ថាបនាជាតិ ១៣៩៦
២៨_៨_១៩៩៦ _ អនុក្រឹត្យលេខ ១៦៤ អនក្រ.តត ស្ដីពីការផ្ដល់មេដាយ
ស្ថាបនាជាតិ ១៣៩៧
២៨_៨_១៩៩៦ _ អនុក្រឹត្យលេខ ១៦៥ អនក្រ.តត ស្ដីពីការផ្ដល់មេដាយ
ស្ថាបនាជាតិ ១៣៩៨
២៨_៨_១៩៩៦ _ អនុក្រឹត្យលេខ ១៦៦ អនក្រ.តត ស្ដីពីការតែងតាំង
សមាសភាព តំណាងប្រមុខរាជរដ្ឋាភិបាល ក្នុងក្រុមប្រឹក្សាភិបាល
ធនាគារជាតិកម្ពុជា ១៣៩៩

២_សេចក្តីសំរេច

២៦-៨-១៩៨៦ - សេចក្តីសំរេចលេខ ៣៥ សសរ ស្តីពីការផ្ទេរសិទ្ធិ ១៤០១

២៨_៦_១៩៨៦ _ សេចក្តីសំរេច លេខ ៣៦ សសរ ស្តីពីការផ្ទេរសិទ្ធិ ១៤០២

III -ការងារបណ្តាក្រសួង

១_ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

ប្រកាស

២៦-៨-១៩៨៦ - ប្រកាសលេខ ៧០៤ អយក.ប្រក ស្តីពីការបង្កើតវិទ្យាល័យ អនុវត្តសំរាប់មហាវិទ្យាល័យគរុកោសល្យ ១៤០៣

៣០-៨-១៩៨៦ - ប្រកាសលេខ ៧១៧ អយក.ប្រក ស្តីពីការអនុញ្ញាតអោយ បោះពុម្ពសៀវភៅរូបវិទ្យា សំរាប់គ្រូថ្នាក់ទី ៧ ១៤០៤

៣០_៨_១៩៨៦ _ ប្រកាស លេខ ៧១៨ អយក.ប្រក ស្តីពីកាអនុញ្ញាតអោយបោះ ពុម្ពសៀវភៅភាសាខ្មែរ សំរាប់គ្រូថ្នាក់ទី ៧ ១៤០៦

២ -ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

២៨-៨-១៩៨៦ - ប្រកាសលេខ ២៥៣/៨៦ ពម.មព.ប្រក ទទួលស្គាល់ លោក VU THE NUNG ជាប្រធានការិយាល័យ និង លោក KIEU CAO KHOAT ជាអ្នកឆ្លើយឆ្លងពត៌មាន របស់ទីភ្នាក់ងារសារពត៌មានវៀតណាម VNA ប្រចាំនៅ ព្រះរាជាណាចក្រកម្ពុជា ១៤០៧

៣- ទីស្តីការក្រសួង ប្រៃសណីយ៍ និងទូរគមនាគមន៍

ប្រកាស

២៦-៨-១៩៨៦ - ប្រកាសលេខ ១៤០ បទ.ប្រក ស្តីពីការតែងតាំងបដិគ្គាហកៈ មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកំពត ១៤០៨

២៦_៨_១៩៩៦ _ ប្រកាសលេខ ១៤១ បទ.ប្រក ស្ដីពីការតែងតាំងបជិត្ថាហក: មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តព្រៃវែង ១៤១០
២៧_៨_១៩៩៦ _ ប្រកាសលេខ ១៤៣ បទ.ប្រក ស្ដីពីការតែងតាំងបជិត្ថាហក: មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ក្រុងព្រះសីហនុ ១៤១១

៣- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សេចក្ដីសំរេច

២៨_៨_១៩៩៦ _ សេចក្ដីសំរេចលេខ ៤៨០ សសរ.មស.ក្រខ ស្ដីពីការបែងចែកសិស្សនិស្សិតចំនួន ២០៤ នាក់ ដែលទើបបញ្ចប់ការសិក្សាពីក្រៅប្រទេស និងក្នុងប្រទេស ១៤១២

I - ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស,រកត,០៨៩៦,៦៥

យើងព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី

* * *

បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានលើកលែងទោសអោយទណ្ឌិតឈ្មោះ **ហែន វិតាគ** ហៅ **ហែន តារៈ** ចំពោះទោសជាប់ពន្ធនាគារ និង ពិន័យ ។

–ទណ្ឌិតឈ្មោះ **ហែន វិតាគ** ហៅ **ហែន តារៈ** ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារកំណត់មួយឆ្នាំ និង ពិន័យជាប្រាក់ ប្រាំលានរៀល តាមអំណាចសាលក្រមលេខ ២៦ « ឃ » ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់តុលាការក្រុងភ្នំពេញ តាមអំណាច សាលដីកាលេខ ៨១ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៥ របស់សាលាឧទ្ធរណ៍ និង តាមសាលដីកាលេខ ១៥ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៦ របស់តុលាការកំពូល ។

មាត្រា ២ : ព្រះរាជក្រឹត្យនេះ មានអានុភាពអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

មាត្រា ៣ : ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង ក្រសួងយុត្តិធម៌ ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេចជាស្ថាពរ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៩៦

ព្រះហស្ថលេខា

នរោត្តម សីហនុ

II - ទីស្តីការគណៈរដ្ឋមន្ត្រី

១_អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១៥០ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

សំរេច

មាត្រា ១ : តែងតាំងលោក **រស់ គង់** បច្ចុប្បន្នប្រធាននាយកដ្ឋានអាហ្វ្រិកមជ្ឈិមបូព៌ា ជាប្រធាននាយកដ្ឋាន កុងស៊ុល ច្បាប់ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការ នៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ នៃស្ថាប័នពាក់ព័ន្ធ និង លោក **រស់ គង់** ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១	**នាយករដ្ឋមន្ត្រីទី២**
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ , ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១៥១ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤_៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤_៩០ ចុះថ្ងៃទី៣១ ខែ តុលា ឆ្នាំ ១៩៩៦ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

សំរេច

មាត្រា ១ : តែងតាំង :

១–លោក **ប៊ិន សុវណ្ណា** ជានាយកខុទ្ទកាល័យ

២–លោក **អ៊ុម គីមឈន** ជាអធិការ នៃអធិការដ្ឋាន

៣–លោក **ឃឹម សារិទ្ធ** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋាន រដ្ឋបាល និង ហិរវត្ថុ

៤–លោក **គិន សំហេង** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋាន រដ្ឋបាល និង ហិរញ្ញវត្ថុ

៥–លោក **អ៊ា ចេងហ៊ាង** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋាន រដ្ឋបាលនិង ហិរញ្ញវត្ថុ

៦–លោក **ពេជ កែវ** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានគ្រប់គ្រង និងការពារបេតិកភ័ណ្ឌវប្បធម៌

៧-លោក **ឃួន ថន** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានគ្រប់គ្រង និង ការពារបេតិកភ័ណ្ឌ វប្បធម៌

៨-លោក **នង ចាន់ថន** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋាន អភិវឌ្ឍន៍ វប្បធម៌ និងវិចិត្រសិល្បៈ

៩-លោក **ស៊ុន សុវណ្ណនី** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ និងវិចិត្រសិល្បៈ

១០-លោក **ជុំ គៀន** ជាសាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ(ថ្នាក់ស្មើអគ្គនាយករង) ។

១១-លោក **ផាន់ សារ៉ាត់** ជាប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ

១២-លោក **ច្នាក់ ឃ្លុយ** ជាប្រធាននាយកដ្ឋានគណនេយ្យ និង ហិរញ្ញវត្ថុ

១៣-លោក **ខឹង ឈង** ជាប្រធាននាយកដ្ឋានសំភារៈ និង បរិក្ខារ

១៤-លោក **ថ្លាំ សំអ៊ាន** ជាប្រធាននាយកដ្ឋានសិក្សាស្រាវជ្រាវ និង គុណភាពការ

១៥-លោក **អ៊ុក សុជាតិ** ជាប្រធាននាយកដ្ឋាន បុគ្គលិក និង កិច្ចការសង្គម

១៦-លោក **ឡុង ទុន្សី** ជានាយកសាលាបណ្តុះបណ្តាលគ្រប់ខ័ណ្ឌវប្បធម៌ (ថ្នាក់ប្រធាននាយកដ្ឋាន)

១៧-លោក **អួង ថន** ជាប្រធាននាយកដ្ឋាន បេតិកភ័ណ្ឌ

១៨-លោក **ឃួន សារម៉េន** ជាប្រធាននាយកដ្ឋាន សារមន្ទីរ

១៩-លោក **អ៊ុន ស៊ីយ៉ុន្តា** ជាប្រធាននាយកដ្ឋានសិល្បៈសូនរូប និង សិប្បកម្ម

២០-លោក **ឌួច ឈួន** ជាប្រធាននាយកដ្ឋាន សៀវភៅ និង ការអាន

២១-លោក **ស៊ឹម សារ៉ាត់** ជាប្រធាននាយកដ្ឋានសកម្មភាពវប្បធម៌ និង ពិព័រណ៍

២២-លោក **ហង្ស សុត** ជាប្រធាននាយកដ្ឋានសិល្បៈទស្សនីយភាព

២៣-លោក **ម៉ុន ណារិទ្ធិ** ជាប្រធាននាយកដ្ឋានសិល្បៈភាពយន្តសោតទស្សន៍ និងផ្សព្វផ្សាយវប្បធម៌

២៤-លោក **ថ្លាំ តារ៉ាទុង** ជាប្រធាននាយកដ្ឋានរៀបចំដែនដីផ្នែកវប្បធម៌

២៥-លោក **គៀង សោភ័ណ្ឌ** ជាព្រឹទ្ធបុរសមហាវិទ្យាល័យស្ថាបត្យកម្ម(ថ្នាក់ស្មើប្រធាន

នាយកដ្ឋាន)

២៦–លោក **ហោ ឡុត** ជាព្រឹទ្ធបុរសមហាវិទ្យាល័យបុរាណវិទ្យា(ថ្នាក់ស្មើប្រធាននាយកដ្ឋាន)

២៧–លោក **អ៊ុង មិញ្ញសិញ្ញ** ជាព្រឹទ្ធបុរសមហាវិទ្យាល័យសិល្បៈសូនរូប (ថ្នាក់ស្មើប្រធាននាយកដ្ឋាន)

២៨–លោក **ទ្បៀង ឈៀង** ជាព្រឹទ្ធបុរសមហាវិទ្យាល័យសិល្បៈនាដសាស្ត្រ(ថ្នាក់ស្មើប្រធាននាយកដ្ឋាន)

២៩–លោក **ទ័ន ផាត** ជាព្រឹទ្ធបុរសមហាវិទ្យាល័យតន្ត្រី(ថ្នាក់ស្មើប្រធាននាយកដ្ឋាន)

៣០–លោក **ជុច គឿន** ជានាយកមជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌(បន្ថែមលើមុខងារជាសាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យវិចិត្រសិល្បៈ)

៣១–លោក **អ៊ុក ចាំ** ជាទីប្រឹក្សា ឯកឧត្តមរដ្ឋមន្ត្រី

៣២–លោក **នឹម វីណា** ទីប្រឹក្សា ឯកឧត្តមរដ្ឋមន្ត្រី

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការមុខងារសាធារណៈ សាមីខ្លួនដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងហត្ថលេខាតទៅ

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៖

អនុក្រឹត្យលេខ ១៥២ អនក្រ.តត

ស្តីពី ការតែងតាំង ទីប្រឹក្សារដ្ឋមន្ត្រី

ក្រសួងមហាផ្ទៃ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៦
- តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ លេខ : ៥៥១ លស ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៦

សំរេច

មាត្រា ១ : ត្រូវបានតែងតាំងជាទីប្រឹក្សារបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជូនអស់លោកដែលមានរាយនាមដូចខាងក្រោម :

១-បណ្ឌិត **និញ ច័ន្ទវិបុល**

២-បណ្ឌិត **ឡៅ ម៉ុងហៃ**

៣-បណ្ឌិត **សុខ ម៉ាធឿន**

៤-លោក **អ៊ុង ស៊ុគែក**

៥-លោក **ខៃ ឆាយលាន**

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តន៍តាមអនុក្រឹត្យនេះចាប់ពី ថ្ងៃឡាយព្រហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១ — ព្រះហស្តលេខា និងត្រា — **នរោត្តម រណឫទ្ធិ**

នាយករដ្ឋមន្ត្រីទី ២ — ហត្ថលេខា និងត្រា — **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១៥៣ អនក្រ.តត

ស្តីពី ការលុបឈ្មោះមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងអនុក្រឹត្យលេខ ៩៤ អនក្រ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៦ ស្តីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ ផ្នែករដ្ឋបាល និង នគរបាលជាតិរបស់ក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : លុបឈ្មោះលោក **ថ្លាង សារុន** អតីតអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ ចេញពីក្របខ័ណ្ឌរដ្ឋ ដោយមូលហេតុមរណភាព ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធា

រណៈ និង ប្រធាន ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

ព្រះហស្តលេខា និងត្រា ហត្ថលេខា និងត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១៥៤ អនក្រ.គត

ស្តីពីការ ជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីកា. តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ. ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩(ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាល ខេត្តកំពង់ចាម

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ ស្ថាបនាជាតិ ជូនចំពោះសប្បុរសជនចំនួន ០៦ រូបដែលបា(បរិច្ចាគ ទ្រព្យសម្បត្តិផ្ទាល់ខ្លួន ចូលរួមជួយកសាង អាគារសិក្សា ជីកប្រឡាយទឹក និ(ផ្តល់ស្រូវពូជ ជូនប្រជាជននៅក្នុងខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោមនេះ ។

ក-មេដាយមាស :

១-ឯកឧត្តម **ហ៊ុន ណេង** បរិច្ចាគប្រាក់ ២៥.០០០ $

២–ឯកឧត្តម **គីង សំណាង** បរិច្ចាគប្រាក់ ១៧.០០០ $ និង ២៥.១៨២.០០០ រៀល

៣–ឯកឧត្តម **គ្រីយ៉ ប៉េងហុង** បរិច្ចាគប្រាក់ ២៨.១៥០ $

៤–ឯកឧត្តម **យូ ស៊ុនឡុង** បរិច្ចាគប្រាក់ ២២.០០០ $

៥–លោក **ម៉ុង ឫទ្ធី** បរិច្ចាគប្រាក់ ៣៣.០០០.០០០ រៀល

ខ_មេដាយប្រាក់ :

១–លោក **សុខ ប៊ុនលីម** បរិច្ចាគប្រាក់ ៥.០០០ $

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាល ខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១៥៥ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស រកត.១០៩៥.០៧ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ ស្ថាបនាជាតិ ជូនចំពោះសប្បុរសជនចំនួន ០៤ រូបដែលបានបរិច្ចាគទ្រព្យសម្បត្តិផ្ទាល់ខ្លួន ចូលរួមជួយកសាងសំណង់សាធារណៈផ្សេងៗ នៅក្នុង ឃុំ ម្រោម ស្រុកអង្គរជ័យ ខេត្តកំពត ដូចមានរាយនាមខាងក្រោមនេះ ។

ក–មេដាយមាស :

១–ឯកឧត្តម **ខួន ម៉ែន** និង លោកជំទាវ បរិច្ចាគ ២៦.០០០.០០០ រៀល

២–លោក **អ៊ឹក សាខន** និង លោកស្រី **ពេជ គីមសួរ** បរិច្ចាគប្រាក់ ៤៣.៩៦០ $

ខ–មេដាយប្រាក់ :

១–លោកយាយ **ឌុច ឆន** នៅសហរដ្ឋអាមេរិក បរិច្ចាគប្រាក់៧.១០០ $

គ_មេដាយសំរិទ្ធ :

១–លោក **ជួប ញ្ញាន់** និង លោកស្រី បរិច្ចាគប្រាក់ ១.៥០០ $

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋលេខាធិការ ក្រសួងធម្មការ និង សាសនា និង អភិបាលខេត្តកំពតត្រូវ អនុក្រឹត្យនេះអោយទទួលបាន លទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៖

អនុក្រឹត្យលេខ ១៥៦ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស រកត.១០៩៥.០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រតិភូ រាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ មាស ស្ថាបនាជាតិ ជូនចំពោះសប្បុរសជនចំនួន ០២ រូប តំណាងអោយក្រុមហ៊ុនសាំងឡេងអន្តរជាតិ ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ជួយកសាងសាលាបឋម សិក្សាសាមគ្គី ក្នុងសង្កាត់ភ្នំពេញថ្មី ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដូចមានរាយនាមខាងក្រោមនេះ ។

១–លោក **ឡើ ហេង** បរិច្ចាគប្រាក់ ១៧.៥០០.$

២–កញ្ញា **អ៊ូ អ៊ីម៉េរ** បរិច្ចាគប្រាក់ ១៧.៥០០ $

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងប្រតិភូរាជរដ្ឋាភិបាល ប្រចាំរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩

អនុក្រឹត្យលេខ ១៥៧ អនក្រ.តត

ស្ដីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស រកត.១០៩៥.០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ ជូនចំពោះសប្បុរសជនជាតំណាងអង្គការ យូស៊ីស៊ីនិងមន្ត្រីសហការដែលបានខិតខំពុះពារអភិវឌ្ឍន៍វិស័យសង្គមកិច្ចនៅក្នុង ខេត្តកំពតចំណាយអស់ថវិកា ចំនួន ៩៦៩.៤៤៦ដុល្លារ សហរដ្ឋអាមេរិក ដូចមានរាយនាមខាងក្រោមនេះ ។

ក-ជូនមេដាយមាសស្ថាបនាជាតិចំពោះអ្នកស្រី **លីនដា ម៉ាកឃីន្លី** តំណាងអង្គការយូស៊ី

ខ-ជូនមេដាយប្រាក់ស្ថាបនាជាតិចំពោះលោក **ដួខ សាវ៉ាន់** ប្រធានអធិការដ្ឋាន សង្គមកិច្ចការងារ និង អតីតយុទ្ធជន ខេត្តកំពត ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន និង អភិបាលខេត្តកំពត ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

ព្រះហស្តលេខា និងត្រា ហត្ថលេខា និងត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១៥៨ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា.
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស រកត.១០៩៥.០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តតាកែវ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយប្រាក់ស្ថាបនាជាតិ ប្រគេនព្រះតេជគុណព្រះមហាថេរ **អ៊ុត ស៊ុម** ដែលបានបរិច្ចាគបច្ច័យផ្ទាល់ព្រះអង្គចំនួន៧.៥០០ $ សំរាប់កសាង អាគារ សិក្សានៅអនុវិទ្យាល័យស្វាគូ ក្នុងស្រុកសំរោង ខេត្តតាកែវ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និ អភិបាល ខេត្តតាកែវ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

ព្រះហស្តលេខា និងត្រា ហត្ថលេខា និងត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩

អនុក្រឹត្យ លេខ ១៥៩ អនក្រ.តត

ស្ដីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីក តែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកា អោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុ ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុ
- តាមសំណើរបស់អភិបាលខេត្តកំពង់ស្ពឺ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ មាសស្ថាបនាជាតិ ជូនចំពោះអង្គការអភិវឌ្ឍន៍ជនបទ ជប៉ុ អាស៊ាន ដែលបានជួយជួសជុល និង កសាងថ្មី នូវអាគារសិក្សាចំនួន ០៥ ខ្នង ក្នុងស្រុកគងពិសី ខេត្តកំពង់ស្ពឺ អស់ទឹកប្រាក់សរុបចំនួន ៦៥.៥៤២ ដុល្ល សហរដ្ឋអាមេរិក ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាល ខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី១	**នាយករដ្ឋមន្ត្រីទី២**
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ១៦០ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ចក្រ៏នៃ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាស អោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាសស្ថាបនាជាតិជូនចំពោះសប្បុរសជន ០២ រូប ដែលបាន បរិច្ចាគទ្រព្យសម្បត្តិផ្ទាល់ខ្លួនចូលរួមជួយកសាងអាគារសិក្សា ដូចមាននាមខាងក្រោម នេះ ÷

១–លោក **គង់ ឫទ្ធីជាតិ** អគ្គនាយកក្លិបយុវជនអន្តរជាតិបរិច្ចាគប្រាក់ ២០.០០០$US កសាង អនុវិទ្យាល័យកោះថ្មី ស្រុកស្អា ខេត្តកណ្តាល ។

២–លោកឧកញ៉ា **ម៉ុង ឫទ្ធី** នាយកក្រុមហ៊ុន **ម៉ុង ឫទ្ធី** បរិច្ចាគប្រាក់១០.០០០$US ជួយជួសជុលអាគារសិក្សានៅឃុំ កោះរការស្រុក កំពង់សៀម ខេត្តកំពង់ចាម ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបា ខេត្តកណ្តាល និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបា លទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៖

អនុក្រឹត្យ លេខ ១៦១ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** វ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ៥ ខែ តុលា ឆ្នាំ ១៩ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

– តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ ជូនសប្បុរសជន ០៣ រូបដែលបានបរិច្ចាគធន ជានផ្ទាល់ខ្លួនចូលរួមជួយសាងសង់អាគារសិក្សា ជីកស្រះទឹក ផ្តល់ម៉ាស៊ីនបូមទឹក និង ស្រូវពូជជូនប្រជារាស្ត្រនៅក្នុងខេត្តកំពង់ស្ពឺ ដូចមានរាយនាមខាងក្រោមនេះ ÷

ក—មេដាយមាសស្ថាបនាជាតិ :

១– ឯកឧត្តម **ហូ សុខ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បរិច្ចាគទឹកប្រាក់ ចំនួន ៣៤.៨៣២ $US

ខ—មេដាយប្រាក់ស្ថាបនាជាតិ :

១–លោកឧកញ៉ា **គង់ ទ្រឹម** បរិច្ចាគទឹកប្រាក់ ចំនួន ៦.០០០$US

២–លោកវរសេនីយ៍ឯក **សួស អង្គារ** បរិច្ចាគទឹកប្រាក់ ចំនួន ៥.២៩០$US

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ១៦២ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់លោកជំទាវ **សោម គីមសួគ៌** តំណាងរាស្ត្រមណ្ឌល កំពត

សំរេច

មាត្រា ១ :ត្រូវបានប្រគល់មេដាយ សិរីវឌ្ឍន៍ ស្ថាបនាជាតិ ជូនលោក **អោម យឿន** ជនជាតិខ្មែររស់ នៅក្រុងស្តុកតុនរដ្ឋកាលីហ្វ័រនីញ៉ា សហរដ្ឋអាមេរិក ដែលបានជួយកសាងសាលាធទាន ជីកស្រះទឹក អណ្តូងស្នប់ និងផ្លូវលំអស់ទឹកប្រាក់សរុប ៣.៧០០$US នៅវត្តសេរីជ័យ មានលក្ខណ៍ ឃុំអង្គរមាស ស្រុកដងទង់ ខេត្តកំពត ។

មាត្រា ២ :សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាល ខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ១៦៣ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា

សំរេច

មាត្រា ១: ត្រូវបានប្រគល់មេដាយមាសស្ថាបនាជាតិជូនលោក ZAINAL ABIDIN និង លោកស្រី H.I.SAFIAH នៃក្រុមហ៊ុនទេសចរណ៍ PRIBOLA SINGAPOUR ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួនចំនួន ១៨.០០០$US សំរាប់ជួយ កសាងវិហារ ឥស្លាម មួយកន្លែងនៅភូមិព្រៃថ្នង ឃុំព្រៃថ្នង ស្រុកកំពង់បាយ ខេត្តកំពត ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋលេខា-ធិការ ក្រសួងធម្មការ និងសាសនា និងអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ១៦៤ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាស អោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ ទីស្តីការគណៈរដ្ឋមន្ត្រី

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ ជូនចំពោះលោក ឧកញ៉ា **សំ អាង** និងលោកជំទាវ **ឈុន ឈាង** ប្រធានក្រុមហ៊ុនវឌ្ឍនៈ អាហារ៍ណ នីហារ៍ណ ដែលបានបរិច្ចាគទឹកប្រាក់១០.០០០$US សំរាប់ជួយកសាងបន្ទប់ VIP នៅព្រលានយន្តហោះអន្តរជាតិ ពោធិចិនតុង ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ១៦៥ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពត

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាសស្ថាបនៈជាតិ ជូនចំពោះឯកឧត្តម **គៀង ម៉ាង** ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួនចំនួន ៣៩.០០០ ដុល្លារសហរដ្ឋអាមេរិក សំរាប់សាងសង់អាគារសិក្សា ០៣ ខ្នង នៅក្នុងសាលាបឋមសិក្សា អេង មាស ឃុំតានី ស្រុកអង្គរជ័យ ខេត្តកំពត ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាល ខេត្តកំពត ត្រូវអនុវត្តតាមអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១ | **នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និងត្រា | ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ | **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ១៦៦ អនក្រ.តត

ស្តីពីការតែងតាំងសមាសភាពតំណាងប្រមុខរាជរដ្ឋាភិបាល

ក្នុងក្រុមប្រឹក្សាភិបាលធនាគារជាតិកម្ពុជា

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦.០១.១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា ។
- តាមសំណើរបស់ទេសាភិបាលនៃធនាគារជាតិកម្ពុជា

សំរេច

